# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុងភ្នំពេញ
លេខ ៣០៣៥ សណន

## ជម្រាបមក

**ឯកឧត្តម ស្នងការនគរបាលរាជធានីភ្នំពេញ**
**ឯកឧត្តម មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ**
**លោក អភិបាលខណ្ឌទាំង ៧**

**កម្មវត្ថុ:** សេចក្តីណែនាំ ស្តីពីការចូលរួមអនុវត្តសាលក្រមតុលាការ ។

**យោង:** ស្មារតីប្រជុំអចិន្ត្រៃយ៍សាលាក្រុងភ្នំពេញ ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៤ ។

-លិខិតេលខ ១៨៨ សជណ. ចុះថ្ងៃទី២១-០៩-២០០៤ របស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តន៍ដីកាសម្រេច លេខ ២០៦៤ តព្រ. ចុះថ្ងៃទី១៦-០៣-២០០៤ របស់តុលាការក្រុងភ្នំពេញ ចំពោះករណីទំនាស់ដីនៅភូមិភ្នំពេញថ្មី និងភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមនិងលោកអភិបាលខណ្ឌជ្រាបថាៈ ក្រោយពីការណែនាំរបស់អង្គប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៦-០៩-២០០៤ សាលាក្រុងភ្នំពេញសង្កេតឃើញថា រាល់ការអនុវត្តន៍សាលក្រមតុលាការទាំងអស់ សាលាខណ្ឌមួយចំនួនបានធ្វើសំណើមកសាលាក្រុងភ្នំពេញខុសពីខ្លឹមសារដែលបានណែនាំ ។

ដើម្បីឱ្យការអនុវត្តន៍បានត្រឹមត្រូវតាមស្មារតីអង្គប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៦-០៩-២០០៤ សាលាក្រុងភ្នំពេញសូមធ្វើការណែនាំដូចតទៅ ៖

១-សាលក្រមតុលាការទាំងអស់ដែលមិនពាក់ព័ន្ធនឹងការរុះរើលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ គឺប្រគល់ឱ្យសាលាខណ្ឌទាំង៧ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញចូលរួមអនុវត្តដូចកន្លងមក ដោយពុំចាំបាច់សុំយោបល់ពីសាលាក្រុងភ្នំពេញជាមុនឡើយ ។ ប៉ុន្តែក្រោយពេលអនុវត្តរួចត្រូវធ្វើរបាយការណ៍មកសាលាក្រុងភ្នំពេញជាបន្ទាន់ ។

២-ចំពោះសាលក្រមតុលាការដែលពាក់ព័ន្ធនឹងការរុះរើលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ត្រូវសុំយោបល់មកសាលាក្រុងភ្នំពេញជាមុន ដើម្បីជៀសវាងនូវបាតុភាពផ្សេងៗ ដូចកន្លងមក ។

អាស្រ័យហេតុនេះ សូមឯកឧត្តម និងលោកអភិបាលខណ្ឌជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារណែនាំខាងលើនេះ ។

ភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៤
**អភិបាលរាជធានីភ្នំពេញ**

**កែប ជុតិមា**

ចម្លងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-តុលាការក្រុងភ្នំពេញ
-ដើម្បីជូនជ្រាប
-ឯកសារ -កាលប្បវត្តិ